ខុមហ្វ្រែល COMFREL

ព្រឹត្តិបត្រ ខុមហ្វ្រែល

# អ្នកឃ្លាំមើល

# NEAK KLOAMMEUL

លេខ៥៨ ឆ្នាំទី២០ ចេញផ្សាយថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥




## មាតិកា

I. បទដ្ឋានសកលសម្រាប់ការសម្រេចសេចក្តីពាក្យបណ្តឹង និងវិវាទនៃការបោះឆ្នោត.....ទំព័រ១-៨

II. អនុសាសន៍សម្រាប់សេចក្តីព្រាង បទបញ្ញា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត...ទំព័រ៨-១

III. របាយការណ៍ សង្ខេបធមាសលើកទី២ នៃការឃ្លាំមើលរដ្ឋសភា និងតំណាងរាស្ត្រនៃនីកាលទី៥..ទំព័រ១៩-២០

IV. សេចក្តីថ្លែងការណ៍រួម ការចាប់ និង ឃុំខ្លួន សកម្មជន បុគ្គលិកអង្គការមាតាធម្មជាតិ ៣ រូបនិង ឃាត់ ខ្លួន បុគ្គលិក អង្គការសង្គមស៊ីវិល និងតំណាងសហគមន៍ ១៧ ជាការរំលោភសិទ្ធិមនុស្ស...ទំព័រ២១

V. សេចក្តីថ្លែងការណ៍រួម អង្គការសង្គមស៊ីវិល សូមអំពាវនាវឲ្យដោះលែងសមាជិកព្រឹត្តសភា គណបក្សជំទាស់ជាបន្ទាន់...ទំព័រ២២-២៨

អ្នកឃ្លាំមើល ៖ ការផ្សាយរបស់ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា

## I. បទដ្ឋានសកលសម្រាប់ការសម្រេចសេចក្តីពាក្យបណ្តឹង និងវិវាទនៃការបោះឆ្នោត

យោងតាមការបោះពុម្ពផ្សាយរបស់ IFES នៅឆ្នាំ២០១១ ស្តីពីសេចក្តីណែនាំទៅលើការសិក្សាស្វែងយល់ការជំនុំជំរះ និងការដោះស្រាយវិវាទនៅក្នុងការបោះឆ្នោត ក្នុងជំពូក១ "បទដ្ឋានអន្តរជាតិ"

### ១.សិទ្ធិប្រកបដោយតម្លាភាពទៅលើដំណោះស្រាយចំពោះភាពមិនប្រក្រតីនៃការបោះឆ្នោត

ការផ្តល់ជាសាធារណៈនូវមធ្យោបាយដែលច្បាស់លាស់មួយ ក្នុងការដោះស្រាយភាពមិនប្រក្រតីនៃការបោះឆ្នោត គឺមានសារៈសំខាន់ណាស់ ក្នុងការរក្សានូវប្រព័ន្ធលើពាក្យបណ្តឹងនៃការបោះឆ្នោតដែលគាំទ្រលើការចូលរួមពីសាធារណជនក្នុងកិច្ចការប្រទេសជាតិប្រកបដោយភាពពេញលេញ។ ទំនុកចិត្តសាធារណៈនឹងផ្តល់ឲ្យអ្នកឈ្នះទទួលបានភាពស្របច្បាប់ដ៏មានសារៈសំខាន់ ក្នុងការគ្រប់គ្រង ដឹកនាំដែលធ្វើឲ្យមានទំនុកចិត្តក្នុងដំណើរការកសាងការស្តារ និងរក្សាលទ្ធិប្រជាធិតេយ្យ។

សិទ្ធិក្នុងការទទួលបានដំណោះស្រាយតម្រូវឲ្យមានដំណើរការគ្រប់គ្រាន់ ក្នុងការបន្តពាក្យបណ្តឹង។ តម្រូវការនេះអំពាវនាវសុំឲ្យស្ថាប័នទាំងនោះ ផ្តល់នូវគោលការណ៍ក្នុងប្រព័ន្ធបណ្តឹងបោះឆ្នោតមួយ ដោយហេតុថា ការដែលកង្វះតម្លាភាពជាមូលដ្ឋានបែបនេះ ជាញឹកញាប់ វាអាចបណ្តាលឲ្យមានការច្រានចោលពាក្យបណ្តឹងស្របច្បាប់លើភាពមិនប្រក្រតី។ តម្លាភាពនៅក្នុងប្រព័ន្ធវិនិច្ឆ័យពាក្យបណ្តឹងបោះឆ្នោត និងដំណើរការនៃការវិនិច្ឆ័យពាក្យបណ្តឹង នឹងបង្កើនទំនុកចិត្តសាធារណៈ ហើយលទ្ធផលនៃពាក្យបណ្តឹង ក៏មានភាពស្របច្បាប់នោះទៅតាមនោះដែរ។ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃសិទ្ធិទទួលបានការដោះស្រាយ អ្នកបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវតែដឹងថាស្ថាប័នណា មានយុត្តាធិការក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងការបោះឆ្នោត និងពាក្យបណ្តឹង ហើយតើថាស្ថាប័ននោះត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច តើអាជ្ញាធរណាជាអ្នកចាត់ដាក់ ឬស្នើសមាជិកនៃស្ថាប័ននោះ និងរបៀបនៃការរៀបចំឯកសារពាក្យបណ្តឹង។ ដែលមានអំណាចដែលតែងតាំង ឬជ្រើសតាំងសមាជិករបស់ខ្លួន និងរបៀបដាក់ពាក្យបណ្តឹង។ រដ្ឋក៏ចាំបាច់ត្រូវច្បាស់លាស់ អំពីអ្នកដែលនាំយកពាក្យបណ្តឹង។ភាពមិនប្រក្រតីក្នុងការបោះឆ្នោតរួមមាន បញ្ហាជាច្រើន ដូចជាសិទ្ធិឈរឈ្មោះជាបេក្ខភាព និងការរាប់សន្លឹកឆ្នោតឡើង ដែលអាចពាក់ព័ន្ធនឹងផលប្រយោជន៍របស់បេក្ខជន គណបក្សនយោបាយ ឬបុគ្គល។ ការកំណត់ថា តើអ្នកណាដែកទទួលបានសិទ្ធិក្នុងការដោះស្រាយក្នុងស្ថានភាពទាំងនោះ គឺជាទិដ្ឋភាពដ៏សំខាន់បំផុតនៃប្រព័ន្ធនេះ។

## I. បទដ្ឋានសកលសម្រាប់ការសម្រេចសេចក្តីពាក្យបណ្តឹង និងវិវាទនៃការបោះឆ្នោត

យោងតាមការបោះពុម្ពផ្សាយរបស់ IFES នៅឆ្នាំ២០១១ ស្តីពីសេចក្តីណែនាំទៅលើការសិក្សាស្វែងយល់ការជំនុំជំរះ និងការដោះស្រាយវិវាទនៅក្នុងការបោះឆ្នោត ក្នុងជំពូក១ "បទដ្ឋានអន្តរជាតិ"

### ១.សិទ្ធិប្រកបដោយតម្លាភាពទៅលើដំណោះស្រាយចំពោះភាពមិនប្រក្រតីនៃការបោះឆ្នោត

ការផ្តល់ជាសាធារណៈនូវមធ្យោបាយដែលច្បាស់លាស់មួយ ក្នុងការដោះស្រាយភាពមិនប្រក្រតីនៃការបោះឆ្នោត គឺមានសារៈសំខាន់ណាស់ ក្នុងការរក្សានូវប្រព័ន្ធលើពាក្យបណ្តឹងនៃការបោះឆ្នោតដែលគាំទ្រលើការចូលរួមពីសាធារណជនក្នុងកិច្ចការប្រទេសជាតិប្រកបដោយភាពពេញលេញ។ ទំនុកចិត្តសាធារណៈនឹងផ្តល់ឲ្យអ្នកឈ្នះទទួលបានភាពស្របច្បាប់ដ៏មានសារៈសំខាន់ ក្នុងការគ្រប់គ្រង ដឹកនាំដែលធ្វើឲ្យមានទំនុកចិត្តក្នុងដំណើរការកសាងការស្តារ និងរក្សាលទ្ធិប្រជាធិតេយ្យ។

សិទ្ធិក្នុងការទទួលបានដំណោះស្រាយតម្រូវឲ្យមានដំណើរការគ្រប់គ្រាន់ ក្នុងការបន្តពាក្យបណ្តឹង។ តម្រូវការនេះអំពាវនាវសុំឲ្យស្ថាប័នទាំងនោះ ផ្តល់នូវគោលការណ៍ក្នុងប្រព័ន្ធបណ្តឹងបោះឆ្នោតមួយ ដោយហេតុថា ការដែលកង្វះតម្លាភាពជាមូលដ្ឋានបែបនេះ ជាញឹកញាប់ វាអាចបណ្តាលឲ្យមានការច្រានចោលពាក្យបណ្តឹងស្របច្បាប់លើភាពមិនប្រក្រតី។ តម្លាភាពនៅក្នុងប្រព័ន្ធវិនិច្ឆ័យពាក្យបណ្តឹងបោះឆ្នោត និងដំណើរការនៃការវិនិច្ឆ័យពាក្យបណ្តឹង នឹងបង្កើនទំនុកចិត្តសាធារណៈ ហើយលទ្ធផលនៃពាក្យបណ្តឹង ក៏មានភាពស្របច្បាប់នោះទៅតាមនោះដែរ។ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃសិទ្ធិទទួលបានការដោះស្រាយ អ្នកបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវតែដឹងថាស្ថាប័នណា មានយុត្តាធិការក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងការបោះឆ្នោត និងពាក្យបណ្តឹង ហើយតើថាស្ថាប័ននោះត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច តើអាជ្ញាធរណាជាអ្នកចាត់ដាក់ ឬស្នើសមាជិកនៃស្ថាប័ននោះ និងរបៀបនៃការរៀបចំឯកសារពាក្យបណ្តឹង។ ដែលមានអំណាចដែលតែងតាំង ឬជ្រើសតាំងសមាជិករបស់ខ្លួន និងរបៀបដាក់ពាក្យបណ្តឹង។ រដ្ឋក៏ចាំបាច់ត្រូវច្បាស់លាស់ អំពីអ្នកដែលនាំយកពាក្យបណ្តឹង។ភាពមិនប្រក្រតីក្នុងការបោះឆ្នោតរួមមាន បញ្ហាជាច្រើន ដូចជាសិទ្ធិឈរឈ្មោះជាបេក្ខភាព និងការរាប់សន្លឹកឆ្នោតឡើង ដែលអាចពាក់ព័ន្ធនឹងផលប្រយោជន៍របស់បេក្ខជន គណបក្សនយោបាយ ឬបុគ្គល។ ការកំណត់ថា តើអ្នកណាដែកទទួលបានសិទ្ធិក្នុងការដោះស្រាយក្នុងស្ថានភាពទាំងនោះ គឺជាទិដ្ឋភាពដ៏សំខាន់បំផុតនៃប្រព័ន្ធនេះ។

## ២.ដំណោះស្រាយដែលបានកំណត់យ៉ាងច្បាស់នៃបទដ្ឋាន និងនីតិវិធីនៃការបោះឆ្នោត

វិធានការនីតិបញ្ញត្តិដែលសមស្របត្រូវតែត្រូវបានទទួលយក ក្នុងគោលបំណងដើម្បីកំណត់សិទ្ធិស្របច្បាប់ដើម្បីដោះស្រាយ និងអនុវត្តការបោះឆ្នោតតាមការកំណត់ ដោយសេរី និងយុត្តិធម៌។ វិធានការទាំងនេះត្រូវតែសរសេរយ៉ាងច្បាស់ និងអាចប្រព្រឹត្តទៅបាននៅក្នុងគោលបំណងដើម្បីផ្តល់សេចក្តីជូនដំណឹងគ្រប់គ្រាន់ និងដំណើរការដល់ការបុគ្គល គណបក្សនយោបាយ និងសង្គមស៊ីវិល។ ខ្លឹមសារនៃច្បាប់ត្រូវតែបានបន្ថែមដោយយន្តការស្របតាមនីតិវិធី ដើម្បីដោះស្រាយជម្លោះដែលបានកើតឡើង។ ក៏ប៉ុន្តែបទដ្ឋាន និងនីតិវិធីដែលមានលក្ខណៈស្មុគស្មាញពេក និងបង្កើតជាឧបសគ្គដល់ការកំណត់នូវដំណោះស្រាយ ភាពមិនប្រក្រតីនៃការបោះឆ្នោត ហើយផ្ទុយទៅវិញ វាក៏ផ្ទុយពីគោលការណ៍មូលដ្ឋាននៃការចូលរួមក្នុងកិច្ចការងារនយោបាយជាសាកល។ ផ្ទុយទៅវិញ ប្រព័ន្ធដែលមិនមានបទដ្ឋាន និងនីតិវិធីរបៀបរៀបរយសោះនោះ វានឹងធ្វើឲ្យមានការបំពានលើការអនុវត្ត យន្តការដោះស្រាយបណ្តឹង។ក្នុងការរៀបចំបទដ្ឋាន និងនីតិវិធីដែលច្បាស់លាស់ ក្នុងការគ្រប់គ្រងករបោះឆ្នោត នឹងអាចកាត់បន្ថយលទ្ធភាពនៃការវិវាទក្រោយការបោះឆ្នោត។

## ៣.អាជ្ញាកណ្តាលដែលមិនលំអៀង និងទទួលព័ត៌មានគ្រប់ជ្រុងជ្រោយ

ការទទួលស្គាល់ពីសារៈសំខាន់នៃអាជ្ញាកណ្តាលដែលមិនលំអៀង និងទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ គឺពាក់ព័ន្ធជាពិសេសនៅពេលដែលត្រូវបានអនុវត្តទៅលើពាក្យបណ្តឹងនៃការបោះឆ្នោតដែលជាទូទៅជាចំណុចរសើបខាងនយោបាយ និងមានភាពចម្រូងចម្រាស់។ ប្រសិនបើរដ្ឋបានលូកដៃចូលក្នុងការប្រតិបត្តិរបស់តុលាការឯករាជ្យ ឬគណៈកម្មការ នោះវានឹងធ្វើឲ្យធ្លាក់ចុះនូវឯករាជ្យភាព និងភាពមិនលំអៀងនៃស្ថាប័ន និងបង្កើតភាពលម្អៀងលើពាក្យបណ្តឹងវិនិច្ឆ័យនៃការបោះឆ្នោត។ លើសពីនេះទៅទៀតដើម្បីឲ្យមានឯករាជ្យភាពប្រកបដោយប្រសិទ្ធភាព ចៅក្រម និងអាជ្ញាកណ្តាលដែលដោះស្រាយពាក្យបណ្តឹងនៃការបោះឆ្នោត គួរតែយល់ដឹងអំពីច្បាប់ដែលទាក់ទងនឹងការបោះឆ្នោតដែលមានស្រាប់ និងមានសមត្ថភាព និងធនធានគ្រប់គ្រាន់ក្នុងការវាយតម្លៃ ធ្វើការស៊ើបអង្កេតពាក្យបណ្តឹង និងដោះស្រាយការពាក់ព័ន្ធទៅនឹងតំបន់ជាក់លាក់មួយនៃច្បាប់។

## ៤.ប្រព័ន្ធដែលគណៈកម្មាធិការវិនិច្ឆ័យអាចធ្វើការសម្រេចចិត្តដោយផ្ទាល់

ផលការបោះឆ្នោត ហេតុដូចនេះ កិច្ចដំណើរការនីតិវិធីបណ្តឹងត្រូវតែបានឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់។ សារៈសំខាន់នៃការកំណត់ពេលវេលា ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងអនុសញ្ញាអន្តជាតិ និងក្នុងតំបន់ និងសន្ធិសញ្ញា ទោះបីជាភាសាជាក់លាក់ដែលអាចប្រែប្រួល។ ឧទាហរណ៍ កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ (ICCPR) អនុសញ្ញារបស់អាមេរិច ស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញា ស្តីពីសិទ្ធិមនុស្សនៅអ៊ឺរ៉ុបបានរកឃើញថា ភាពបន្ទាន់នៃពេលវេលា ក្នុងការដោះស្រាយពាក្យបណ្តឹងទាមទារឲ្យចាត់វិធានការនៅក្នុងអំឡុងពេលមួយជាក់លាក់ និងសមស្រប ដោយមិនមានការពន្យារពេលហួសហេតុពេក។

### ៥.ការដាក់បន្ទុកបង្កើតឡើងនៃភស្តុតាង និងបទដ្ឋានភស្តុតាង

គោលការណ៍មួយទៀតនៅក្នុងការដោះស្រាយពាក្យបណ្តឹងនៃការបោះឆ្នោត គឺជាការបង្កើតភស្តុតាងនៃការដាក់បន្ទុកដោយយុត្តិធម៌ និងភស្តុតាងដែលមានបទដ្ឋាន។ គោលការណ៍ណែនាំទាំងនេះ ត្រូវតែបង្កើតឡើងមុនពាក្យបណ្តឹង ដើម្បីឲ្យភាគីដែលពាក់ព័ន្ធទទួលបាននូវការជូនដំណឹង និងយល់ដឹងពីហេតុផលនៃអ្វីដែលត្រូវបានទាមទារពីភាគីទាំងសងខាង ក្នុងគោលបំណងដើម្បីដោះស្រាយបញ្ហានេះ។ ទោះជាយ៉ាងណា រដ្ឋជាអ្នកកំណត់ដើម្បីជ្រើសរើសនូវបទដ្ឋានរបស់ខ្លួន ដោយនិយមន័យនេះ គួរតែត្រូវបានដឹងឮពីគណបក្សទាំងពីរ និងតុលាការនៅមុនពេលសវនាការចាប់ផ្តើម និងសំខាន់ជាងនេះទៀត គឺមុនពេលដែលការបោះឆ្នោតត្រូវបានធ្វើឡើង។

នៅពេលដែលបានកំណត់ស្តង់ដារនេះហើយ ចាំបាច់ត្រូវមានការគោរពទៅតាមនីតិវិធីទាំងស្រុង។ បើមិនដូច្នេះទេ ជាឧទាហរណ៍ ប្រសិនបើការអនុវត្តន៍បទដ្ឋានអាដហុក ដែលជាការជំនុំ ជម្រះបណ្តឹង ឬការលាតត្រដាងបង្ហាញផ្សេងគ្នាក្នុងសកម្មភាពស្រដៀងគ្នា ដោយយោងទៅតាមបទដ្ឋានផ្សេងគ្នា នោះវានឹងត្រូវបានចាត់ទុកចូលទៅក្នុងសំណួរដើម្បីស្វែងរកភាពត្រឹមត្រូវ និងភាពមិនលម្អៀងនៃការជនុំជម្រះបណ្តឹង ហើយវាក៏នឹងបង្កឲ្យមានការសង្ស័យលើភាពស្របច្បាប់នៃដំណើរការទាំងមូល (និងអាចធ្វើទៅបាននៃការបោះឆ្នោតទាំងមូល) ដោយមិនគិតពីលទ្ធផលនៃដំណើរការនេះ។

### ៦.ពេលវេលាដែលអាចធ្វើទៅបាននៃដំណោះស្រាយដែលមានអត្ថន័យនិង ប្រសិទ្ធភាព

យន្តការបណ្តឹង ដែលមានភាពប្រាកដប្រជា ត្រូវតែផ្តល់នូវដំណោះស្រាយដែលមានប្រសិទ្ធភាពទាន់

ពេលវេលា និងអាចដំណើរការអនុវត្តបាន។ អនុសញ្ញាផ្នែកច្បាប់អន្តរជាតិយល់ស្របថា នៅពេលប្រទេសមួយដែលបានកំណត់ពីសិទ្ធិគ្រប់គ្រាន់ និងត្រូវបានរៀបចំឡើងនូវនីតិវិធីរបស់ខ្លួន ដំណើរការនៃការបង្កើតបានលទ្ធផល សមស្របជាការចាំបាច់ដូចគ្នា។ សេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្សបានកត់សម្គាល់ពីសារៈសំខាន់នៃ(សិទ្ធិដើម្បីជាសំណងសម្រេចដោយតុលាការជាតិ ដែលមានសមត្ថកិច្ចចំពោះអំពើរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន ដែលបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់)។ ភាសានេះត្រូវបានឆ្លុះបញ្ចាំងដោយស្ទើរគ្រប់ឯកសារច្បាប់អន្តរជាតិសំខាន់ៗ បើទោះជាពួកគេអាចប្រើពាក្យផ្សេងគ្នា ប្រព័ន្ធសិទ្ធិមនុស្សនៅក្នុងតំបន់ជាច្រើនក៏ផ្តល់សិទ្ធិដល់បុគ្គលប្រហាក់ប្រហែលគ្នា។

**៧.ការអប់រំដ៏មានប្រសិទ្ធភាពរបស់ភាគីពាក់ព័ន្ធ**

ដូចបានរៀបរាប់ខាងលើ ទំនុកចិត្តសាធារណៈ គឺជាធាតុសំខាន់នៅក្នុងដំណើរការបោះឆ្នោតមានប្រសិទ្ធភាព។ រដ្ឋមានកាតព្វកិច្ចធានាឲ្យបានថា ភាគីពាក់ព័ន្ធជាមួយនឹងការទទួលខុសត្រូវសម្រាប់ទិដ្ឋភាពនៃដំណើរការបោះឆ្នោតនេះ ត្រូវទទួលបានការបណ្តុះបណ្តាលសមស្រប។ រដ្ឋគួរអនុវត្តកម្មវិធីបណ្តុះបណ្តាលសម្រាប់បុគ្គលិកបំពេញការងារបោះឆ្នោត ក៏ដូចជាកម្មវិធីអប់រំពលរដ្ឋវិជ្ជាថ្នាក់ជាតិ ដែលនឹងអនុញ្ញាតឲ្យសាធារណជនយល់ដឹងពីនីតិវិធី និងបញ្ហានៃការបោះឆ្នោត។ វាជាការសំខាន់ដែលសាធារណជនទទួលបាននូវព័ត៌មាន និងអាចចូលដំណើរការបានយ៉ាងងាយស្រួល និងទូលំទូលាយ ក្នុងការបោះឆ្នោតទូទៅនោះ ប៉ុន្តែអ្វីដែលសំខាន់ លើសពីនេះទៅទៀត គឺសិទ្ធិដែលផ្តល់ដល់ពួកគេ ដើម្បីដោះស្រាយភាពមិនប្រក្រតីនៃការបោះឆ្នោត។ ភាគីពាក់ព័ន្ធដែលបានចូលរួមនៅក្នុងដំណើរការវិនិច្ឆ័យ ពាក្យបណ្តឹងបោះឆ្នោត មានតម្រូវការទទួលបាននូវវគ្គបណ្តុះបណ្តាលផ្សេងៗគ្នា ដូច្នេះកម្មវិធីអប់រំ និងការណ្តុះបណ្តាលគួរកំណត់គោលដៅនៃក្រុមបុគ្គលជាមួយនឹងគោលដៅរួមនៃការលើកកំពស់ការយល់ដឹងទូទៅនៃដំណើរកាវិនិច្ឆ័យពាក្យបណ្តឹងបោះឆ្នោត។

## II. អនុសាសន៍សម្រាប់សេចក្តីព្រាង បទបញ្ញា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត

ល.រ　សេចក្តីព្រាងបទបញ្ញា និងនីតិវិធី　អនុសាសន៍ និងមូលហេតុ

## ជំពូក១៖ ការគ្រប់គ្រងការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតឆ្នាំ២០១៦

### ខ្លឹមសារសង្ខេបអនុសាសន៍ជំពូកទី១៖

- កំណត់សន្ទស្សន៍គុណភាពបញ្ជីឈ្មោះបោះឆ្នោតថ្មីយ៉ាងតិច៩៨% (មិនមានឈ្មោះស្ទួន និងមានទិន្នន័យក្នុងបញ្ជីដែលមិនបាត់សិទ្ធិបោះឆ្នោត)
- កំណត់ភារកិច្ច ស្មៀនឃុំ/សង្កាត់ដែលជាអនុប្រធាន ក.ច.ប ត្រឹមជាជំនួយការប្រធាន ក.ច.ប
- បន្ថយការទទួលបន្ទុកនៃការងារអប់រំផ្សព្វផ្សាយបោះឆ្នោតរបស់ក្រុមប្រឹក្សាឃុំសង្កាត់ មកត្រឹមជំនួយការអប់រំផ្សព្វផ្សាយ

| | | |
|---|---|---|
| ១ | -ការកំណត់ការរៀបចំបញ្ជីបោះឆ្នោតធានាបានភាពពេញលេញ ត្រឹមត្រូវនឹងមានសុពលភាពល្អ (ប្រការ១.១) | -ពេញលេញត្រឹមត្រូវ និងមានសុពលភាពនៃបញ្ជីឈ្មោះបោះឆ្នោតត្រូវមានកំរិត៩៨%យ៉ាងតិច(មិនមានឈ្មោះស្ទួន និងមានទិន្នន័យក្នុងបញ្ជីដែលមិនបាត់សិទ្ធិបោះឆ្នោត)។(មូលហេតុដោយសារមានការសាកល្បងរួចហើយដោយ ខុមហ្វ្រែល និងអ៊ីរ៉ា (ERA) បានបង្ហាញឲ្យឃើញថា ប្រព័ន្ធកុំព្យូទ័រជាមួយនិងប្រព័ន្ធជីវមាត្រ(Biometric) និងសមត្ថភាពយុវជនធានាភាពត្រឹមត្រូវរហូតដល់ ៩៩%)។ |
| | **រចនាសម្ព័ន្ធថ្នាក់ក្រោម គ.ជ.ប ក្នុងដំណាក់ការបោះឆ្នោត** | |
| ២ | -តួនាទី និងភារកិច្ចស្មៀន ឃុំសង្កាត់ក្នុងក្រុមចុះឈ្មោះបោះឆ្នោត(ប្រការ១.២.៤) | -ស្មៀនឃុំសង្កាត់ជាអនុប្រធានក្រុមចុះឈ្មោះបោះឆ្នោតគួរមានភារកិច្ចជាជំនួយការឲ្យប្រធានក្រុមចុះឈ្មោះបោះឆ្នោត។ ដូចនេះសមាជិកនៃក្រុមចុះឈ្មោះបោះឆ្នោតមានចំនួន៤នាក់ រួមទាំងស្មៀនឃុំសង្កាត់។ សមាជិកនៃក្រុមត្រូវធ្វើប្រតិបត្តិការជាក់ស្តែងដែលមានតែបីនាក់តែងតាំងដោយ គ.ជ.ប ។ (ពីព្រោះស្មៀនឃុំសង្កាត់មានតួនាទីសំខាន់ណាស់សម្រាប់បន្តនិរន្តរភាពនៃការងារ និងធ្វើលិខិត ព្រមទាំងកិច្ចការរដ្ឋបាលផ្សេងៗរបស់ឃុំសង្កាត់។ |

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់(គបឃស)

| | | |
|---|---|---|
| ៣ | ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបន្ទុកការងារអប់រំ។ (ប្រការ ១.៦.២.៦ និងប្រការ ១.៦.២.៧) | -ក្រុមប្រឹក្សាឃុំ សង្កាត់ មានភារកិច្ចជាជំនួយការក្នុងការផ្តល់ព័ត៌មាននៃការចុះឈ្មោះបោះឆ្នោត និងសម្របសម្រួលភាគីពាក់ព័ន្ធដែលចូលរួមធ្វើការអប់រំដល់ប្រជាពលរដ្ឋមានសិទ្ធិចុះឈ្មោះបោះឆ្នោត។ ការងារទទួលបន្ទុកអប់រំរបស់ គ.ជ.ប។ និងឬលេខាធិការដ្ឋានរៀបចំការបោះឆ្នោតរាជធានី ខេត្ត។ (ព្រោះថាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាគណបក្សនយោបាយ។ ការអប់រំសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដល់ប្រជាពលរដ្ឋ អាចបង្កើតបញ្ហាលម្អៀងខាងនយោបាយ និងពួកគាត់មានការរវល់ច្រើន។ ម្យ៉ាងទៀត ជំពូក២ ចែងថា គ.ជ.ប ត្រូវធ្វើការអប់រំការបណ្តុះបណ្តាលផ្សព្វផ្សាយបោះឆ្នោត)។ |

## នីតិវិធីជ្រើសរើស កចប

| | | |
|---|---|---|
| ៤ | លក្ខខណ្ឌបច្ចេកទេសសម្រាប់សមាជិកក្រុមចុះឈ្មោះបោះឆ្នោត(ប្រការ១.៧.២.៥) | សមាជិកក្រុមចុះឈ្មោះបោះឆ្នោតចេះប្រើប្រាស់កុំព្យូទ័រ ដែលអាចវាយបញ្ចូលឈ្មោះឲ្យបានបី(៣)ឈ្មោះយ៉ាងតិច ក្នុងមួយនាទី។ (ព្រោះការសាកល្បងរបស់ ERA បានបង្ហាញថា មានយុវជននៅមូលដ្ឋានដែលមានសមត្ថភាពវាយបញ្ចូលឈ្មោះបានប្រាំក្នុងមួយនាទីក្នុងកុំព្យូទ័រ។) |

## សមាសភាព

| | | |
|---|---|---|
| ៥ | -ប្រការ ១.៨.១/២/៣ | -ក.ច.ប ត្រូវមានសមាជិកត្រឹមចំនួន០៤រូប ដែលរួមបញ្ចូលទាំងស្មៀនឃុំ/សង្កាត់។ សម្រាប់ការចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ/សង្កាត់ធំ ត្រូវបន្ថែមក្រុមចុះឈ្មោះបោះឆ្នោត។ (មូលហេតុៈ ដើម្បីធានាគុណភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវរបស់ ក.ច.ប និងសំរួលដល់ដំណើរការចុះឈ្មោះចល័តនៅតាមភូមិ) |

ជំពូកទី៣៖ ការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត

ខ្លឹមសារសង្ខេបអនុសាសន៍ជំពូកទី៣៖

- ត្រូវបើកចំហទិន្នន័យនៃបញ្ជីឈ្មោះ ទីតាំងនៃការិយាល័យដែលអាចវិភាគបានដោយកុំព្យូទ័រ
- កំណត់តួនាទី និងភារកិច្ចនៃនាយកដ្ឋានប្រតិបត្តិការក្នុងផ្នែកដាច់ដោយឡែកក្នុងជំពូកនេះ។

## ការិយាល័យបោះឆ្នោត

| | | |
|---|---|---|
| ៦ | -នៅក្នុងភូមិណាដែលមានប្រជាពលរដ្ឋតិចជាងមួយរយ គ.ជ.ប ត្រូវបញ្ចូលឈ្មោះអ្នកភូមិទាំងនោះទៅក្នុងបញ្ជីបោះឆ្នោតទៅភូមិណាមួយផ្សេងទៀតដែលនៅជិតភូមិនោះ។ (ប្រការ ៣.៣.៦) | -គ.ជ.ប ត្រូវសិក្សា តើមានភូមិប៉ុន្មានដែលមានប្រជាពលរដ្ឋតិចជាងមួយរយ ដែលអាចកំណត់ចំនួនអប្បរមានៃបញ្ជីឈ្មោះបោះឆ្នោតនៅតាមភូមិណាមួយ។ (ព្រោះថាដើម្បីឲ្យគ.ជ.បពិនិត្យ និងកំណត់ឡើងវិញចំនួនប្រជាពលរដ្ឋដែលត្រូវទៅចុះឈ្មោះនៅភូមិណាមួយផ្សេង)។ |

## ការផ្សព្វផ្សាយទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោតថ្មីឆ្នាំ២០១៥

| | | |
|---|---|---|
| ៧ | -ការផ្សព្វផ្សាយពេលវេលាប្រតិទិនសម្រាប់ការចុះឈ្មោះនៅតាមឃុំ សង្កាត់(ប្រការ៣.៥.២ និងប្រការ ៣.៥.៣) | -ការផ្សព្វផ្សាយពេលវេលាប្រតិទិនសម្រាប់ការចុះឈ្មោះនៅភូមិឲ្យបានយ៉ាងតិចមុនពីរថ្ងៃ មុនថ្ងៃចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋ។ |
| ៨ | -អង្គការក្រៅរដ្ឋាភិបាល គណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មានអាចស្នើសុំបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត(ប្រការ ៣.៥.៨) | -អង្គការក្រៅរដ្ឋាភិបាល គណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន អាចស្នើសុំទិន្នន័យនៃបញ្ជីឈ្មោះទីតាំងនៃការិយាល័យ ដែលអាចវិភាគបានដោយកុំព្យូទ័រ។ (ពីព្រោះទិន្នន័យនេះងាយស្រួលក្នុងការធ្វើសវនកម្ម និងមានការបង់សោហ៊ុយតិចផងដែរ)។ |

## ជំពូកទី៤៖ ដំណើរការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦

## ខ្លឹមសារសង្ខេបអនុសាសន៍ជំពូក៤៖

- មន្ត្រី ក.ច.ប ត្រូវបំពេញទំរង់សំណួរក្នុងដំណើរចុះឈ្មោះ(មានភ្ជាប់ជាមួយឧបសម្ព័ន្ធ)
- បង្កើតការផ្ទៀងផ្ទាត់រវាងមន្ត្រី ក.ច.ប និងអ្នកចុះឈ្មោះបោះឆ្នោត ទៅលើបណ្ណព័ត៌មានចុះឈ្មោះបោះឆ្នោត (បង្កាន់ដៃចុះឈ្មោះបោះឆ្នោតដែលព្រីនចេញពីកុំព្យូទ័រ ជាមួយឯកសារបញ្ជាក់អត្តសញ្ញាណ)
- គ.ជ.ប គ្មានសិទ្ធិកែប្រែ ឬផ្លាស់ប្តូរទិន្នន័យអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចហើយ
- ត្រូវបន្ថែម ព្រីនទ័រ ក្នុងសំភារៈចុះឈ្មោះបោះឆ្នោត ដើម្បីព្រីនប័ណ្ណព័ត៌មានចុះឈ្មោះបោះឆ្នោត(បង្កាន់ដៃចុះឈ្មោះបោះឆ្នោត)

- ត្រូវព្រីន(Print) និងបញ្ជាក់ឯកសារបញ្ជាក់អត្តសញ្ញាណដើម្បីបោះឆ្នោត (ICV) ក្រោយពេលចុះឈ្មោះបោះឆ្នោតរួចភ្លាមសម្រាប់អ្នកដែលមិនមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

## សង្ខេបដំណាក់ការនៃការចុះឈ្មោះបោះឆ្នោត

១-ការបិទផ្សាយ

២-ការចុះឈ្មោះ និងបញ្ជូនតាម online

៣-ការចងក្រងបញ្ជីឈ្មោះបោះឆ្នោតដំបូង

៤-ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង

៥-ការដោះស្រាយបណ្ដឹង និងការសរុបបញ្ចប់

| | | |
|---|---|---|
| ៩ | ២-ការចុះឈ្មោះបោះឆ្នោត និងបញ្ជូនតានប្រព័ន្ធអ៊ីនធឺនេតមកមជ្ឈមណ្ឌលកុំព្យូទ័រ គ.ជ.ប ប្រការ(៤.១.២)<br>៣-ការចងក្រង និងកត់ត្រាទិន្នន័យសម្រាប់រៀបចំបញ្ជីបោះឆ្នោតដំបូង(ប្រការ ៤.១.៣)<br>៤-ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង<br>៥-ការដោះស្រាយបណ្ដឹង (ប្រការ៤.១.៥) | ២-ចុះឈ្មោះបោះឆ្នោតហើយ ត្រូវធ្វើការផ្ទៀងផ្ទាត់កែតម្រូវទិន្នន័យដោយក្រុមចុះឈ្មោះបោះឆ្នោតជាមួយអ្នកចុះឈ្មោះបោះឆ្នោត។(ព្រោះថា អាចជានាភាពត្រឹមត្រូវ)<br>៣-បន្ទាប់ពីកែសម្រួលលើទិន្នន័យដោយក្រុមចុះឈ្មោះបោះឆ្នោត និងមានការបញ្ជូនទិន្នន័យតាម online មក NECC ដើម្បីចងក្រង និងរៀបចំបញ្ជីដំបូង។ គ.ជ.បឬ/និងNECC មានសិទ្ធិលុបឈ្មោះស្ទួន។<br>៤-NECC ត្រូវបញ្ជូនជាសារអេឡិចត្រូនិចឬ/និងដាក់បញ្ចូលក្នុង website មកក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីយកបញ្ជីបោះឆ្នោតដំបូងទៅផ្សព្វផ្សាយ។<br>៥-ដោះស្រាយបណ្ដឹងជំទាស់នៃបញ្ជីបោះឆ្នោតដំបូងតែប៉ុណ្ណោះ ដែល គ.ជ.ប សម្រេចលុប ឬរក្សាឈ្មោះ (ព្រោះថា គ.ជ.ប ឬ NECC មិនត្រូវធ្វើការកែតម្រូវឈ្មោះទៀតទេ។ មានន័យថា គ្មានបណ្ដឹងតវ៉ាដើម្បីកែតម្រូវទេ មានតែបណ្ដឹងជំទាស់ ឲ្យលុបឈ្មោះអ្នកគ្មានសិទ្ធិ ឬរួមទាំងការលុបឈ្មោះស្ទួន។) |

## រយៈពេលនៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ

| | | |
|---|---|---|
| ១០ | -រយៈពេលនៃការចុះឈ្មោះបោះឆ្នោតនៅតាម ឃុំ សង្កាត់នីមួយៗ។(ប្រការ ៩.២) | ការចុះឈ្មោះបោះឆ្នោត និងការកែតម្រូវដោយក្រុមចុះឈ្មោះត្រូវមានរយៈពេល៩០ថ្ងៃយ៉ាងតិច មុននឹងចងក្រង និងបង្កើតបញ្ជីដំបូង។ (ព្រោះថា រយៈពេលនេះជាមួយចំនួនក្រុមចុះឈ្មោះបោះឆ្នោតយ៉ាងតិច២៥០០ក្រុម សម្រាប់អ្នកចុះឈ្មោះបោះឆ្នោតប្រហែល១០លាននាក់។) |

## សម្ភារៈ បរិក្ខារ ឯកសារបម្រើការចុះឈ្មោះបោះឆ្នោត

| | | |
|---|---|---|
| ១១ | នាយកដ្ឋានប្រតិបត្តិការ។(ប្រការ៩.៣.១) | -នាយកដ្ឋានប្រតិបត្តិការ ត្រូវតែចែងក្នុងជំពូកទី១ ក្នុងផ្នែកដោយឡែក និងចែងឲ្យច្បាស់ពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវ។ (ព្រោះថានាយកដ្ឋាននេះជាអង្គភាពសំខាន់មួយដែលមានការទទួលខុសត្រូវការងារចុះឈ្មោះបោះឆ្នោត និងការគ្រប់គ្រងទិន្នន័យ) |

## ដំណើរប្រព្រឹត្តទៅនៃការចុះឈ្មោះបោះឆ្នោត

| | | |
|---|---|---|
| ១២ | -ការបញ្ចូលឈ្មោះទៅក្នុងកុំព្យូទ័រ ត្រូវធ្វើតាមប្រព័ន្ធបិទ (Offline) ប៉ុន្តែនៅពេលបញ្ចូលទិន្នន័យបាន១០នាក់ម្តង ការីកុំព្យូទ័រត្រូវបើកប្រព័ន្ធអ៊ីនធឺណេត ដើម្បីបញ្ចូលទិន្នន័យទាំងនោះ មកប្រព័ន្ធផ្ទុកទិន្នន័យបញ្ជីឈ្មោះបោះឆ្នោតនៅ គ.ជ.ប មជ្ឈមណ្ឌលកុំព្យូទ័រ។(ប្រការ ៩.៩.១០) | -ការបញ្ចូលឈ្មោះទៅក្នុងកុំព្យូទ័រ ត្រូវធ្វើតាមប្រព័ន្ធបិទ (Offline) ប៉ុន្តែនៅពេលបញ្ចូលទិន្នន័យ និងកែតម្រូវចប់រួចរាល់ពេលល្ងាចម៉ោងប្រាំការីកុំព្យូទ័រត្រូវបើកប្រព័ន្ធអ៊ីនធឺណេត ដើម្បីបញ្ចូលទិន្នន័យទាំងនោះមកប្រព័ន្ធផ្ទុកទិន្នន័យបញ្ជីឈ្មោះបោះឆ្នោតនៅ គ.ជ.ប ប មជ្ឈមណ្ឌលកុំព្យូទ័រ។ (ព្រោះថាមិនចាំបាច់កំណត់ចំនួនក្នុងការបញ្ជូនទិន្នន័យតាម Online ទេ ដើម្បីទុកពេលវេលាឲ្យសមាជិកក្រុមបំពេញការងារចុះឈ្មោះ)។ |
| ១៣ | -នៅរៀងរាល់ពេលបញ្ចប់ការចុះឈ្មោះបោះឆ្នោតតាមថ្ងៃនីមួយៗ ការីកុំព្យូទ័រត្រូវធ្វើបច្ចុប្បន្នភាពទិន្នន័យទាំងនេះដើម្បីបញ្ជូនតាមប្រព័ន្ធអ៊ីនធឺណេត មក គ.ជ.ប។ ក្រុមចុះឈ្មោះមិនអាចប្រើប្រាស់ ឬកែប្រែ ឬផ្លាស់ប្តូរទិន្នន័យដែល | -ក្នុងអំឡុងពេលចុះឈ្មោះ បន្ទាប់ពីការផ្ទៀងផ្ទាត់ ត្រឹមត្រូវហើយ ការកែប្រែត្រូវបិទ ហើយទាល់តែធ្វើបច្ចុប្បន្នភាពឆ្នាំក្រោយទើបបើកសិទ្ធិឡើងវិញ។<br>-គ.ជ.ប ក៏មិនមានសិទ្ធិកែប្រែតម្រូវដែរ (ព្រោះថាត្រូវពង្រឹងការទទួលខុសត្រូវ និងសន្តិសុខទៅលើការកែតម្រូវ |

| | | |
|---|---|---|
| | បានបញ្ជូនចេញរួចហើយនោះបានទេ។ (ប្រការ៤.៤.១២) | ទិន្នន័យ។ ក្រោយពេលចុះឈ្មោះបោះឆ្នោតគ្មាននណាម្នាក់ឲ្យសិទ្ធិចូលកែត្រូវទិន្នន័យទេ។) |
| ១៤ | -សម្ភារៈសម្រាប់ការចុះឈ្មោះបោះឆ្នោតតាមប្រព័ន្ធកុំព្យូទ័រខាងលើរួមមាន៖<br>១.កុំព្យូទ័រ Laptop មួយគ្រឿង<br>២.ម៉ៅ(MOUSE)<br>៣.ម៉ូនីទ័រ ចំនួន ០១(មួយ)<br>៤.ម៉ាស៊ីនស្កេនមេដៃចំនួន០១(មួយ)<br>៥.USB Digital Camera ថតរូបចំនួន០១ (មួយ)<br>៦.ផ្ទាំងក្រណាត់ពណ៌ផ្ទៃមេឃមួយផ្ទាំងសម្រាប់ធ្វើផ្ទៃថតរូប<br>៧.USB Flash Drive ចំនួន០២(ពីរ)<br>៨.Switch and UPS សម្រាប់ក្រុមចុះឈ្មោះមានកុំព្យូទ័រចាប់ពី០៣(បី)គ្រឿងឡើង<br>៩.ម៉ាស៊ីនភ្លើងមួយគ្រឿង(សម្រាប់ឃុំសង្កាត់គ្មានអគ្គិសនីរដ្ឋ។)<br>(ប្រការ៤.៤.១៣ ) | -សម្ភារៈសម្រាប់ការចុះឈ្មោះបោះឆ្នោតរួមមាន៖<br>១.កុំព្យូទ័រ Laptop មួយគ្រឿង<br>២.ម៉ាស៊ីនថតរូបមួយគ្រឿង<br>៣.ម៉ាស៊ីនស្កេនមេដៃចំនួន០១ (ជាប្រភេទប្រើប្រាស់ទិន្នន័យ Bio-matric)<br>៤.ម៉ាស៊ីនភ្លើងមួយគ្រឿង(សម្រាប់ឃុំសង្កាត់គ្មានអគ្គិសនីរដ្ឋ ឬចរន្តអគ្គិសនីរអាក់រអួល)<br>៥.ម៉ាស៊ីនបោះពុម្ព(PRINTER) មួយគ្រឿង។ (ព្រោះថាម៉ាស៊ីនបោះពុម្ព សំខាន់ណាស់ ដើម្បីបោះពុម្ពប័ណ្ណព័ត៌មានអ្នកចុះឈ្មោះបោះឆ្នោតជំនួសទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត)។ |

## ជំហានទាំង៥នៃការចុះឈ្មោះបោះឆ្នោត

| | | |
|---|---|---|
| ១៥ | -ជំហានទី១៖ ប្រធានក្រុមចុះឈ្មោះត្រូវសាកសួរព័ត៌មានដូចតទៅ:<br>-តើអ្នកមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែរឬទេ?<br>-តើអ្នកធ្លាប់ចុះឈ្មោះដែរឬទេ?នៅកន្លែងណា?ពេលណា?(ប្រការ៤.៤.១៦) | ជំហានទី១៖ អ្នកសុំចុះឈ្មោះ ត្រូវជួបជាមួយ ប្រធានក្រុមចុះឈ្មោះបោះឆ្នោតដើម្បីធ្វើសម្ភាសន៍ និងបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតតាមទម្រង់ និងបញ្ជីសំណួរចុះឈ្មោះបោះឆ្នោត (សូមមើលក្នុងឧបសម្ព័ន្ធទី១ រូបគំរូទី១ ស្តីពីទម្រង់ និងបញ្ជីសំណួរចុះឈ្មោះបោះឆ្នោត)។ទម្រង់ និងបញ្ជីសំណួរនេះ នឹងផ្តល់ព័ត៌មានសង្ខេបចំពោះអ្នកសុំចុះឈ្មោះឧទាហរណ៍ ពិការភាព និងបញ្ជាក់ការទទួលខុសត្រូវរបស់មន្ត្រីចុះឈ្មោះបោះឆ្នោត។អនុប្រធានក្រុមចុះឈ្មោះបោះឆ្នោត(ស្មៀន) ជាជំនួយការប្រធានក្នុងប្រតិបត្តិ |

| | | |
|---|---|---|
| ១៦ | ជំហានទី២៖ ក្នុងករណីអ្នកសុំចុះឈ្មោះ បានបំពេញតាមលក្ខខណ្ឌកំណត់រួម ប្រធានត្រូវណែនាំឲ្យអ្នកសុំចុះឈ្មោះមកជួបអនុប្រធានចុះឈ្មោះបោះឆ្នោតដើម្បីបន្តនីតិវិធីចុះឈ្មោះបោះឆ្នោតតាមជំហានបន្តបន្ទាប់។ ប្រការ(៤.៤.១៨) | ជំហានទី២៖ អ្នកសុំចុះឈ្មោះជួបសមាជិកទី១នៃចុះឈ្មោះបោះឆ្នោតជាការីកុំព្យូទ័រ ដើម្បីវាយបញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រត្រូវថតរូប និងផ្តិតមេដៃអ្នកសុំចុះឈ្មោះបោះឆ្នោត ហើយនិងធ្វើការផ្ទៀងផ្ទាត់ឈ្មោះស្ទួន(តាមរយៈស្នាមក្រយៅមេដៃជាគោល)។ សមាជិកទី១ ត្រូវបោះពុម្ព(ព្រីន) ប័ណ្ណព័ត៌មានអ្នកសុំចុះឈ្មោះបោះឆ្នោត(មើលក្នុងឧបសម្ព័ន្ធរូបគំរូទី២ដែលជំនួសទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត។ |
| ១៧ | ជំហានទី៣៖ អនុប្រធានក្រុមចុះឈ្មោះបោះឆ្នោតត្រូវ<br>-បំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត(ទ.១០២២)ដោយផ្អែកតាមទិន្នន័យក្នុង អ.ខ ឬ ឯ.ង។(ប្រការ ៤.៤.២០)<br>ជំហានទី៤៖ សមាជិកក្រុមចុះឈ្មោះបោះឆ្នោត ដែលជាការីត្រូវកត់ត្រាទិន្នន័យ អ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រដូចខាងក្រោម៖(ប្រការ៤.៤.២២) | ជំហានទី៣៖ សមាជិកទី២នៃក្រុមចុះឈ្មោះបោះឆ្នោត ត្រូវធ្វើការផ្ទៀងផ្ទាត់ទិន្នន័យ ក្នុងប័ណ្ណព័ត៌មានអ្នកចុះឈ្មោះបោះឆ្នោតជាមួយនឹងឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតនោះ។ ករណីខុសព័ត៌មានណាមួយអ្នកពិនិត្យត្រូវគូសរង្វង់ចំណាំ រួមបញ្ជូនឲ្យសមាជិកទីមួយដើម្បីធ្វើការកែសម្រួលឲ្យបានត្រឹមត្រូវឡើងវិញ។ (ព្រោះថាការផ្ទៀងផ្ទាត់ទិន្នន័យ រវាងក្រុមចុះឈ្មោះបោះឆ្នោត និងអ្នកចុះឈ្មោះបោះឆ្នោត គឺសំខាន់ណាស់ក្នុងការធានាភាពត្រឹមត្រូវទិន្នន័យហើយបន្ទាប់មកបិទការកែតម្រូវ |
| ១៨ | **ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតគ្មាន អ.ខ**<br>-ប្រការ ៤.៤.២៣) | សម្រាប់អ្នកដែលមិនមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនោះ ឯកសារបញ្ជាក់អត្តសញ្ញាណដើម្បីបោះឆ្នោត (ICV) ត្រូវការព្រីន (print) ចេញពីកុំព្យូទ័រ ហើយចុះហត្ថលេខាដោយសមាជិកក្រុមចុះឈ្មោះបោះឆ្នោត(តំណាងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត(CEC) និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬស្មៀនឃុំ សង្កាត់(តំណាងឲ្យអាជ្ញាធរឃុំ សង្កាត់)។ ករណីនេះ គ.ជ.ប និងក្រសួងមហាផ្ទៃ គួរធ្វើសេចក្តីណែនាំរួម ដោយមានការបញ្ជាក់អំពីភាពជាតំណាងគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត និងអាជ្ញាធរឃុំសង្កាត់។ (ព្រោះថាការចេញឯកសារបញ្ជាក់អត្ត |

សញ្ញាណ ដើម្បីបោះឆ្នោត ដល់អ្នកចុះឈ្មោះបោះឆ្នោត ដែលគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរភ្លាមក្រោយពេលចុះឈ្មោះបោះឆ្នោតបន្ថយបន្ទុកការទៅរកឯកសារទាំងនេះហើយធានាថា អ្នកចុះឈ្មោះបោះឆ្នោតទាំងនោះមានឯកសារនេះ។)

**ជំពូកទី៥៖ ការដាក់ទទួលអង្កេត និងដោះស្រាយបណ្តឹងទាក់ទិនការចុះឈ្មោះបោះឆ្នោត**

**ខ្លឹមសារសង្ខេបអនុសាសន៍ជំពូក៥៖**

- ការដាក់ និងទទួលពាក្យបណ្តឹង៖ ត្រូវទទួលពាក្យបណ្តឹង និងជួយសរសេរបណ្តឹងចំពោះអ្នកប្តឹងមិនមានសមត្ថភាពសរសេរពាក្យបណ្តឹង
- បន្ថែមយន្តការអង្កេតបណ្តឹង (ស្រាវជ្រាវ ផ្ទៀងផ្ទាត់ និងប្រមូលភស្តុតាង) លើបទល្មើសដាក់ពិន័យ និងដកសិទ្ធិបោះឆ្នោត
- បង្កើតគណៈកម្មការទទួល និងអង្កេតបណ្តឹងនៅ គ.ជ.ប
- គ.ជ.ប ត្រូវកំណត់ពេលវេលាសម្រាប់អង្កេត
- កែសម្រួលពេលវេលាអង្កេត និងដោះស្រាយពាក្យបណ្តឹង នៅក្រុមប្រឹក្សាធម្មនុញ្ញ
- បង្កើតសៀវភៅណែនាំនីតិវិធីសម្រាប់គណៈកម្មការទទួល/អង្កេត ពាក្យបណ្តឹង
- សវនាការរបស់ គ.ជ.ប ដូមជា សវនាការសង្ខេប សវនាការប្រតិបក្ស និងសវនាការដេញដោល ត្រូវធ្វើជាសាធារណៈ
- បង្កើតយន្តការពិសេសសម្រាប់អង្កេត និងដោះស្រាយបណ្តឹងបាត់ឈ្មោះដែលបានចុះបញ្ជីរួចហើយ
- មិនមានយន្តការបណ្តឹងតវ៉ា(ការកែតម្រូវឈ្មោះ ឬទិន្នន័យ)នៅពេលបិទបញ្ជីដំបូង ប៉ុន្តែមានបណ្តឹងជំទាស់

ត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) ដើម្បីគ្រប់គ្រងទិន្នន័យដែលត្រូវបានផ្សព្វផ្សាយ។

**ផ្នែកទី១៖ ការដាក់ទទួលអង្កេត និងដោះស្រាយបណ្តឹងទាក់ទងការចុះឈ្មោះបោះឆ្នោត**

(មូលហេតុបន្ថែមការអង្កេត គឺដើម្បីពង្រឹងការដោះស្រាយបណ្តឹងទាក់ទិនការចុះឈ្មោះបោះឆ្នោត។ ស្ថាប័នខ្លះមិនមានភារកិច្ចដោះស្រាយ ប៉ុន្តែស្ថាប័ននោះមានភារកិច្ចអង្កេតបន្ថែម ដូចជាគណៈកម្មការទទួលពាក្យបណ្តឹង អង្កេតរបស់រដ្ឋសភា)

| | | |
|---|---|---|
| ១៩ | **គោលការណ៍ទូទៅ**<br>-ជនណាក៏ដោយ ឬអ្នកតំណាំងមានសិទ្ធិប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់....ប្រសិនជាមានភស្តុតាង បញ្ជាក់ថា មានភាពមិនត្រឹមត្រូវ...(ប្រការ៥.១)<br>-ពាក្យបណ្ដឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ តាម ទ.១២០២....(ប្រការ៥.១.១) | -បើមានពាក្យបណ្ដឹងក្រុមប្រឹក្សាឃុំ/សង្កាត់(កបឃ/ស) ឬគណកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)ឬក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែទទួល បើទោះជាគ្មានភស្តុតាងគ្រប់គ្រាន់នៅពេលប្ដឹងក៏ដោយ។ (មូលហេតុះរយៈពេលនៃការដាក់ពាក្យបណ្ដឹងខ្លីដែលភាគីដើមបណ្ដឹងពិបាកក្នុងការស្វែងរកភស្តុតាងដាក់បន្ទុកឲ្យគ្រប់គ្រាន់។ ម្យ៉ាងទៀត កបឃ/ស ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញត្រូវធ្វើការអង្កេតស្វែងរកការពិត នៅពេលមានពាក្យបណ្ដឹងណាមួយ។)<br>-មន្ត្រីទទួលពាក្យបណ្ដឹង មានភារកិច្ចជួយសរសេរពាក្យបណ្ដឹង។ (មូលហេតុះដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋ ដែលមករកពាក្យបណ្ដឹង) |
| ២០ | **ការដាក់/ទទួលពាក្យបណ្ដឹងនៅ គ.ជ.ប**<br>-....ពាក្យបណ្ដឹងពុំបានធ្វើឡើង ក្នុងអំឡុងពេល... មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវចុះពេលវេលា...ដាក់ជូន គ.ជ.ប ចារបដិសេធ...(ប្រការ៥.២.១១)<br>-...ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹង គ្រប់ច្បាប់...(ប្រការ៥.២.១២) | -គ.ជ.ប ត្រូវមានសៀវភៅណែនាំនីតិវិធីលម្អិត ស្ដីអំពីការទទួលពាក្យបណ្ដឹង នឹងការអង្កេតសម្រាប់គណៈកម្មការទទួលពាក្យបណ្ដឹង និងអង្កេតទាក់ទងការចុះឈ្មោះបោះឆ្នោត។ (មូលហេតុះ បទបញ្ជា និងនីតិវិធីជំពូក៥ ទាក់ទងបណ្ដឹង គឺមិនទាត់ច្បាស់លាស់នៅឡើយទេ ដើម្បីឲ្យគណៈកម្មការនេះអនុវត្តការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព)។ |
| ២១ | **អង្កេតទាក់ទងករណីបណ្ដឹង**<br>-សេចក្ដីព្រាងបទបញ្ជា និងនីតិវិធី មិនមានចែងពីយៈពេលនៃការអង្កេតករណីបណ្ដឹងទេ។ | -គណៈកម្មការទទួលបណ្ដឹង និងអង្កេតទាក់ទងការចុះឈ្មោះបោះឆ្នោត ត្រូវធ្វើការអង្កេតករណីនៃពាក្យបណ្ដឹងក្នុងរយៈពេលមួយ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹង។ (មូលហេតុះដើម្បីឲ្យគណៈកម្មការនេះមានពេលវេលាក្នុងការអង្កេតអំពីការពិតចំពោះករណីពាក្យ |

| | | |
|---|---|---|
| | | បណ្តឹង។ ម្យ៉ាងវិញទៀត គ.ជ.ប អាចមានចំណាត់ការបណ្តោះអាសន្ន ទាន់ពេលវេលា ចំពោះមិនប្រក្រតីនោះ។) |
| ២២ | **ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប**<br>-គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈ សម្រេចលើបណ្តឹងក្នុងរយៈពេលប្រាំ(៥)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។(ប្រការ ៥.២.១៥) | -គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈ សម្រេចលើបណ្តឹង ក្នុងរយៈពេលបី(៣)ថ្ងៃយ៉ាងយូរ បន្ទាប់ពីការអង្កេត។ (មូលហេតុះគណៈកម្មការទទួលពាក្យបណ្តឹង និងអង្កេតទាក់ទងការចុះឈ្មោះបោះឆ្នោតត្រូវមានពេលវេលាអង្កេតរួចរាល់ហើយ ដូច្នេះត្រូវការពេលវេលាដើម្បី(មិនច្រើនទេ)បើកសវនាការសម្រេចបណ្តឹងជាបន្ទាន់។) |
| ២៣ | **សវនាការសម្រេចបណ្តឹងរបស់ គ.ជ.ប**<br>-....គ.ជ.ប បើកសវនាការសម្រេចបដិសេធ ឬយល់ព្រមលើបណ្តឹងតវ៉ា.... | -សវនាការសង្ខេប សវនាការប្រតិបក្ស និងសវនាការសួរដេញដោលរបស់ គ.ជ.ប ត្រូវធ្វើឡើងជាសាធារណៈ។ (មូលហេតុះ ដើម្បីធានាឲ្យមានតម្លាភាពនៃការដោះស្រាយបណ្តឹងរបស់ គ.ជ.ប និងធានាឲ្យភាគីពាក់ព័ន្ធចូលរួមដោយពេញលេញ។) |
| ២៤ | **ការដោះស្រាយបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ**<br>-ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចលើពាក្យបណ្តឹងតវ៉ាដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេល១០(ដប់)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលពាក្យបណ្តឹង។(ប្រការ៥.២.២១) | -ក្រុមប្រឹក្សាធម្មនុញ្ញ គួរមានពេលវេលាក្នុងការងារអង្កេតបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។<br>-ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបើកសវនាការសាធារណៈ ក្នុងរយៈពេលមួយបន្ទាប់ពីអង្កេត។(មូលហេតុះដើម្បីផ្តល់រយៈពេលដល់ក្រុមប្រឹក្សាធម្មនុញ្ញធ្វើការអង្កេតរកការពិតធ្វើជាមូលដ្ឋានសម្រាប់ការសម្រេចសេចក្តីរបស់ខ្លួន។) |

## ផ្នែកទី២៖ ការដាក់ទទួលអង្កេត និងដោះស្រាយបណ្តឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតបំបូង

បន្ថែម - អង្កេត - ដូចផ្នែកទីមួយដែរ

| | | |
|---|---|---|
| ២៥ | គោលការណ៍ទូទៅ<br>-ជនណាក៏ដោយមានសិទ្ធិប្ដឹងតវ៉ាឬ/និង ជំទាស់ជាលាយលក្ខណ៍អក្សរតាម ទ.១២០២...(ប្រការ ៥.៣) | ជនណាក៏ដោយ មានសិទ្ធិប្ដឹងជំទាស់ ជាលាយលក្ខណ៍អក្សរតាម ទ.១២០២..។(មូលហេតុះក្នុងដំណាក់កាលនេះមិនមានការប្ដឹងតវ៉ាករណីកែតម្រូវទិន្នន័យអ្នកចុះឈ្មោះបោះឆ្នោតទេ។ ក្រុមចុះឈ្មោះបោះឆ្នោតបានធ្វើការផ្ទៀងផ្ទាត់ទិន្នន័យជាមួយអ្នកចុះឈ្មោះបោះឆ្នោតរួចរាល់ហើយ នៅអំឡុងពេលចុះឈ្មោះបោះឆ្នោត។)ក្នុងករណីប្ដឹងទាក់ទិន "ការបាត់ និងផ្ទៀងផ្ទាត់ករណីនេះឲ្យបានលំអិត រវាងឯកសារ និងបច្ចេកទេស ដោយគណៈកម្មការទទួលពាក្យបណ្ដឹង និងអង្កេតជាមួយនាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធនានា។ (មូលហេតុះករណីបាត់ឈ្មោះមិនកើតមានឡើយ បើប្រព័ន្ធចុះឈ្មោះបោះឆ្នោតមានសុវត្ថិភាព។)ឈ្មោះ" គ.ជ.ប ត្រូវមាននីតិវិធីពិសេសដើម្បីពិនិត្យ |
| ២៦ | ការដាក់/ទទួលការអង្កេតការដោះស្រាយពាក្យបណ្ដឹង និងការធ្វើសវនាការរបស់ គ.ជ.ប<br>-ក្នុងករណី គ.ជ.បប្រសម្រេចជុំបដិសេធមិនទទួលពាក្យបណ្ដឹង គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធ។(ប្រការ ៥.៣.១៩) | អនុសាសន៍ដូចក្នុងចំណុចទី២ ទី៣ ទី៤ និងទី៥។ |
| ២៧ | **ការដោះស្រាយពាក្យបណ្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ** | អនុសាសន៍ដូចក្នុងចំណុចទី៦។ |

## ព័ត៌មានស្ដីអំពីការដាក់ទទួល អង្កេត/និងការដោះស្រាយបណ្ដឹង

| | | |
|---|---|---|
| ២៨ | -ទំរង់បែបបទទាំងអស់នឹងត្រូវបង្ហោះនៅលើគេហទំព័ររបស់ គ.ជ.ប។ បន្ថែមលើសពីនេះទៅទៀត រាល់ឯកសារដែលត្រូវផ្សព្វផ្សាយជាសាធារណៈ ដូចជាកំណត់ហេតុសវនាការ របាយការណ៍ប្រជុំសម្រេចសេចក្ដីសម្រេច | -បទបញ្ញត្តិនេះក៏ត្រូវបានយកទៅអនុវត្តចំពោះផ្នែកទី២ អំពីការដាក់ទទួលអង្កេត និងដោះស្រាយបណ្ដឹងទាក់ទង និងបញ្ជីឈ្មោះបោះឆ្នោតដំបូង។<br>-គ.ជ.ប ត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) ដើម្បីគ្រប់គ្រងព័ត៌មានត្រូវបានផ្សព្វផ្សាយទាំងនោះ។ |

នានាលើបណ្តឹង។ល។ ក៏ត្រូវបានបង្ហោះនៅលើគេហទំព័ររបស់ គ.ជ.ប នៅថ្ងៃដែលធ្វើហើយ។(៥.១.៥)

(មូលហេតុះដើម្បីពង្រឹងតម្លាភាព និងការសិក្សាស្រាវជ្រាវចំពោះយន្តការបណ្តឹងពាក់ព័ន្ធ និងការចុះឈ្មោះបោះឆ្នោត)។

## ឧបសម្ព័ន្ធ

### ទម្រង់ ពាក្យស្នើសុំចុះឈ្មោះបោះឆ្នោត លេខ ....................

ក្រុមចុះឈ្មោះបោះឆ្នោតលេខ:........ ឃុំ/សង្កាត់.................................................................

☐ លធ/ខប ☐ រាជធានី/ខេត្ត...............................................................

១.ខ្ញុំបាទ នាងខ្ញុំបានសុំចុះឈ្មោះបោះឆ្នោត និងសូមធានាអះអាងថា ព័ត៌មានឯកសារពិតជាត្រឹមត្រូវ។ (អាបជូនអ្នកស្នើសុំចុះឈ្មោះបោះឆ្នោត)

២-តើអ្នកធ្លាប់បានចុះឈ្មោះបោះឆ្នោតឬ/និងបោះឆ្នោតកន្លងមកដែរឬទេ? ☐ ធ្លាប់ ☐ មិនធ្លាប់

បើ "ធ្លាប់" ចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំណា(ចុងក្រោយ)..............................។

៣-ឈ្មោះអ្នកសុំចុះឈ្មោះបោះឆ្នោត......................ភេទ ☐ស្រី ☐ប្រុស អាយុ:..........ឆ្នាំ

៤.ឯកសារបញ្ជាក់អត្តសញ្ញាណថាមានសិទ្ធិបោះឆ្នោត

☐ក.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

☐ខ.ឯកសារបញ្ជាក់អត្តសញ្ញាំផ្សេងៗ................................។

៥.ឯកសារខាងលើពិតជាបំពេញលក្ខខណ្ឌនៃការចុះឈ្មោះបោះឆ្នោត

| | មាន | មិនមាន |
|---|---|---|
| ក.សញ្ជាតិខ្មែរ | ☐ | ☐ |
| ខ.និងគ្រប់អាយុ១៨ឆ្នាំ និងឡើងទៅ | ☐ | ☐ |

៦.ការសង្កេតឃើញថា:

☐មិនអាចនិយាយ ឬយល់ភាសាខ្មែរទាល់តែសោះ ☐ ពិការធ្ងន់ធ្ងរ(ពិបាកក្នុងការបោះឆ្នោត)

☐បុព្វជិតសាសនា

៧.ទីតាំងសម្រាប់ការចុះឈ្មោះបោះឆ្នោត

☐ នៅទីតាំងក្នុងឯកសារបញ្ជាក់អត្តសញ្ញាណប្រើប្រាស់សម្រាប់ចុះឈ្មោះបោះឆ្នោត

☐ ទីតាំងផ្សេងទៀតនៃកន្លែងចុះឈ្មោះបោះឆ្នោត

៨.បានសម្ភាសន៍ បានសង្កេត និងបានឃើញឯកសារ

**ហត្ថលេខាប្រធានក្រុមចុះឈ្មោះបោះឆ្នោត**

បានផ្ទៀងផ្ទាត់ទិន្នន័យរួមទាំងស្នាមមេដៃ និងរូបថតអ្នកស្នើសុំចុះឈ្មោះបោះឆ្នោតក្នុងប្រព័ន្ធ កុំព្យូទ័រ ឃើញថា:

☐ បានស្នាមមេដៃក្នុងប្រព័ន្ធកុំព្យូទ័រ(មិនអនុញ្ញាតឲ្យចំឈ្មោះបោះឆ្នោត ☐ មិនមានក្នុងប្រព័ន្ធកុំព្យូទ័រ

☐មិនអាចយកស្នាមមេដៃ(ពិការ)

**ហត្ថលេខានៃសមាជិកទី១ នៃក្រុមចំឈ្មោះបោះឆ្នោត**

១០.បានផ្ទៀងផ្ទាត់ព័ត៌មានក្នុងប័ណ្ណព័ត៌មានអ្នកចុះឈ្មោះបោះឆ្នោតឡើងវិញជាមួយអ្នកចុះឈ្មោះបោះឆ្នោត ហើយបានប្រគល់ប័ណ្ណអ្នកចុះឈ្មោះបោះឆ្នោតបញ្ជាក់ការចុះឈ្មោះបោះឆ្នោតទៅឲ្យអ្នកចុះឈ្មោះបោះឆ្នោត។

ហត្ថលេខា និងស្នាមមេដៃអ្នកចុះឈ្មោះបោះឆ្នោត ហត្ថលេខា សមាជិកទី២ នៃក្រុមចុះឈ្មោះបោះឆ្នោត

**រូបគំរូទី២៖ ប័ណ្ណព័ត៌មានអ្នកចុះឈ្មោះបោះឆ្នោត(RVN)**

**ព្រះរាជាណាចក្រកម្ពុជា**

**គណៈកម្មការជាតិរៀបចំការបោះឆ្នោត**

**ប័ណ្ណព័ត៌មានអ្នកចុះឈ្មោះបោះឆ្នោត**



ឈ្មោះ .គែវ សុធា .ភេទ ប្រុស

ផលិតថ្ងៃទី១ ខែមករា ឆ្នាំ២០១៤

អាស័យដ្ឋាន និងទីតាំងទៅបោះឆ្នោត

ការិយាល័យបោះឆ្នោត ០០០១ទីតាំងវត្តអូរអណ្ដូង

នៅ #១E0 ផ្លូវលេខ ១២២ ក្រុម ០១

ភ.បន្ទាយនាង ឃ.បន្ទាយនាង ខ.បន្ទាយមានជ័យ

ចំណាំ: ប័ណ្ណនេះមិនបំរើឲ្យការបោះឆ្នោតទេ

រូបគំរូទី៣៖ ឯកសារបញ្ជាក់អត្តសញ្ញាណដើម្បីបោះឆ្នោត(ICV)

Logo

**ព្រះរាជាណាចក្រកម្ពុជា**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**



លេខ......................................

**ឯកសារបញ្ជាក់អត្តសញ្ញាណដើម្បីបោះឆ្នោត**

នាម និង គោត្តនាមៈ កែវ សុផាំ  ភេទប្រុស....ថ្ងៃខែឆ្នាំកំណើតៈ០១.០១.១៩៩០

មានអាស័យដ្ឋាន និងទីតាំងទៅបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត ០០០១ ទីតាំងវត្តអូរអណ្តូង និងទីលំនៅផ្ទះលេខ#១E0 ផ្លូវលេខ១២២ក្រុម០១ ភូមិ.បន្ទាយនាង ឃុំ/សង្កាត់បន្ទាយនាង

ខេត្តបន្ទាយមានជ័យ

យើងខ្ញុំជាក្រុមប្រឹក្សាឃុំសង្កាត់ និងជាគណៈកម្មការឃុំរៀបចំការបោះឆ្នោត បានពិនិត្យនិងចេញឯកសារបញ្ជាក់នេះ

ជូនសាមីខ្លួនប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៨ ស្របតាមការកំណត់នៃច្បាប់។

## III.របាយការណ៍សខ្ទេបឆមាសទី២ នៃការឃ្លាំមើលរដ្ឋសភា និងតំណាងរាស្ត្រ នៃនីតិកាលទី៥

ក្នុងរយៈពេលចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០១៥ ការសង្កេតឃើញថា សកម្មភាពរបស់គណៈកម្មការ ជំនាញរដ្ឋសភា និងចំនួនសកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមានភាពល្អប្រសើរជាងរយៈពេលដូចគ្នាក្នុងដើមនីតិកាលនេះ។ ផ្ទុយទៅវិញ ការពិភាក្សា និងអនុម័តច្បាប់ហាក់មិនសូវមានគុណភាព និងធ្វើឡើងដោយប្រញាប់ប្រញាល់។ ខាងក្រោមជារបាយការណ៍រកឃើញចំណុចសំខាន់ៗ។

**ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ:** ក្នុងរយៈពេលនេះមានតំណាងរាស្ត្រចំនួន៧០រូប មកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានចុះធ្វើសកម្មភាពក្នុងមូលដ្ឋានចំនួន៦១២លើក។ បើប្រៀបធៀបក្នុង រយៈពេលដូចគ្នាក្នុងឆ្នាំទី១នៃនីតិកាលទី៥នេះ ការសង្កេតឃើញថា ចំនួនសក្មមភាពមានការកើនឡើង ប៉ុន្មានចំនួនតំណាងរាស្ត្រធ្វើសកម្មភាពមានការថយចុះតិចតួច ដែលក្នុងរយៈពេលនោះមានតំណាងរាស្ត្រចំនួន៧៨រូប ចុះធ្វើសកម្មភាពបានចំនួន៥០០លើក។ មូលហេតុសំខាន់នៃការកើនឡើងចំនួនសកម្មភាព ជាពិសេសតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ ព្រោះថាក្រុមតំណាងរាស្ត្រទាំងនោះបានចូលរដ្ឋសភា ដែលបង្កលក្ខណៈងាយស្រួលក្នុងការធ្វើសកម្មភាពជាងក្នុងនាមជាបក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ។

រយៈពេល៦ខែ ដើមឆ្នាំទី២ នីតិកាលទី៥នេះ ខុមហ្វ្រែលទទួលព័ត៌មានពីការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចំនួន ៣៨រូប ចុះធ្វើសក្មមភាពក្នុងមូលដ្ឋានបានចំនួន ៨៥លើក។ ចំណែកគណបក្សសង្គ្រោះជាតិមានតំណាងរាស្ត្រចំនួន ៣២រូប បានចុះធ្វើសក្មមភាពក្នុងមូលដ្ឋានរបស់ខ្លួនចំនួន ៥២៧លើក។

**សកម្មភាពរបស់គណៈកម្មការជំនាញរបស់រដ្ឋសភា:** សកម្មភាពរបស់គណៈកម្មការជំនាញមានការកើនឡើងគួរឲ្យកត់សម្គាល់ទាំងគណៈក្មមការជំនាញដឹកនាំដោយគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ដែលក្នុងរយៈពេលនេះមានសកម្មភាពរហូតដល់ ៥៥លើក។ រដ្ឋមន្ត្រីចំនួន ៨រូប ត្រូវបានហៅមកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងគណៈកម្មការជំនាញរដ្ឋសភា និងនៅក្នុងក្រសួងសាមី។ គួរបញ្ជាក់ថា សកម្មភាពដែលខុមហ្វ្រែលបានរាប់បញ្ចូលរួមមានការកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺក្នុងគណៈកម្មការជំនាញ និងជួបពិភាក្សានៅសាមីក្រសួងពាក់ព័ន្ធ សកម្មភាពទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងការចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរមានសមត្ថកិច្ច ឬ/និងប្រជាពលរដ្ឋ ឬតំណាងអង្គការសង្គមស៊ីវិល និងព្រមទាំងសកម្មភាពចុះទៅដល់កន្លែងដែលមានទំនាស់ផ្សេងៗ។

**ដំណើរការប្រជុំពេញអង្គរបស់រដ្ឋសភា:** រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គសាមញ្ញ១លើក និងវិសាមញ្ញ១លើក ដែលមានកិច្ចប្រជុំសរុបចំនួន១០លើក។ របៀបវារៈចំនួន១៥ ត្រូវបានរដ្ឋសភាពលើកមកពិភាក្សា និងអនុម័ត ហើយក្នុងនោះរួមមានការបោះឆ្នោតជ្រើសតាំងសមាជិក គ.ជ.ប និងសមាជិកគណៈកម្មការជំនាញរដ្ឋសភា។





សេចក្តីថ្លែងការណ៍ស្តីពីរបាយការណ៍សង្ខេបឆមាសទី២ នៃការឃ្លាំមើលរដ្ឋសភា និងតំណាងរាស្ត្រ នៃនីតិកាលទី៥

## IV.សេចក្តីថ្លែងការណ៍រួម ការចាប់ និងឃុំខ្លួន សកម្មជន បុគ្គលិកអង្គការមាតាធម្មជាតិ ៣ រូប និងឃាត់ខ្លួន បុគ្គលិក អង្គការសង្គមស៊ីវិល និងតំណាងសហគមន៍ ១៧ ជាការរំលោភសិទ្ធិមនុស្ស

អង្គការសង្គមស៊ីវិលដែលមានឈ្មោះដូចខាងក្រោម ថ្កោលទោសចំពោះសកម្មភាពរបស់ អាជ្ញាធរខេត្តកោះកុង ដែលបានឃុំខ្លួនបុគ្គលិកអង្គការមាតាធម្មជាតិចំនួន៣នាក់ និងឃាត់ខ្លួនបុគ្គលិកអង្គការសង្គមស៊ីវិល និងសហគមន៍ចំនួន១៧នាក់។

កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ អាជ្ញាធរខេត្តកោះកុង បានចាប់ និងឃុំខ្លួនបុគ្គលិកអង្គការមាតាធម្មជាតិចំនួន៣នាក់ រួមមាន លោក សាន់ ម៉ាឡា លោក ទ្រី សុរិគា និងលោក ស៊ឹម សំណាង ដោយសាលាដំបូងខេត្តកោះកុង ចោទពីបទ "គំរាមកំហែងដែលនឹងធ្វើអោយខូចខាតដោយភ្ជាប់នឹងបញ្ជាអ្វីមួយ" តាមមាត្រា៤២៤ នៃក្រមព្រហ្មទណ្ឌ។ ក្រោយមក នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ សមត្ថកិច្ចខេត្តកោះកុង បានឃាត់ខ្លួនមនុស្សចំនួន១៧នាក់បន្ថែមទៀត ដែលក្នុងនោះមាន បុគ្គលិកអង្គការសង្គមស៊ីវិលចំនួន៧នាក់ គ្រូពេទ្យចំនួន១នាក់ និងតំណាងសហគមន៍ ចំនួន ៩ នាក់។ ការចាប់ខ្លួននេះបានកើតឡើង ដោយសារតែសហគមន៍ និងបុគ្គលិកមាតាធម្មជាតិទាមទារដោយសន្តិវិធីមិនឲ្យសាឡង់ បូមខ្សាច់នៅក្នុងព្រែកស្ថិតក្នុងឃុំអណ្តូងទឹក ស្រុកបុទុមសាគរ ខេត្តកោះកុង ដែលសាឡង់បូមខ្សាច់នោះបានបូមខ្សាច់ អស់រយៈពេល ៦ ឆ្នាំ មកហើយ។

អង្គការសង្គមស៊ីវិលសង្កេតឃើញថា ការបូមខ្សាច់ ដោយក្រុមហ៊ុន Direct Access Co., Ltd និងក្រុមហ៊ុន International Rainbow Co., Ltd បានធ្វើអោយប៉ះពាល់ដល់បរិស្ថាន ដូចជាធ្វើអោយបាត់បង់ព្រៃកោងកាង បាត់បង់ជំរកត្រីខូចទឹក និងបាត់បង់ជីវចំរុះ ជាពិសេសទៅទៀតនោះ ការបូមខ្សាច់នេះ បានធ្វើអោយប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋ ដែលធ្វើអោយមានសំលេងរំខានដល់ការរស់នៅរបស់អ្នកស្រុក កុមារបោះបង់សាលារៀន មានជំងឺប្រចាំកាយ និងមានការចំណាកស្រុកថែមទៀតផង។ លើសពីនេះទៅទៀត ការធ្វើអាជីវកម្មបានរំលោភអាជ្ញាប័ណ្ណ លេខ ៣១៥ រថ.រស.អប របស់ក្រសួងរ៉ែ និងថាមពល ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៤ ដូចជា ការបូមលើសជំរៅ (ក្នុងអាជ្ញាប័ណ្ណកំណត់ជំរៅ ២-៥ម៉ែត្រ តែជាក់ស្តែងជំរៅដែលជ្រៅជាងគេ ១៦.៦ម៉ែត្រ) និងគំលាតពីច្រាំង (ក្នុងអាជ្ញាប័ណ្ណកំណត់ ជិតជាងគេ ៣០ ម៉ែត្រ និងឆ្ងាយបំផុត ២០០ម៉ែត្រ តែជាក់ស្តែងគំលាតពីច្រាំង ១០ម៉ែត្រ) ។

អង្គការសង្គមស៊ីវិលយល់ឃើញថា សកម្មភាពទាមទារមិនអោយសាឡង់បូមខ្សាច់បន្តទៀត ពីសំណាក់បុគ្គលិកមាតាធម្មជាតិ និងប្រជាពលរដ្ឋនៅក្នុងតំបន់នោះ គឺជាការចូលរួមយ៉ាងសំខាន់ក្នុងការការពារបរិស្ថាន ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិ រីឯការចាប់ខ្លួនពួកគេគឺជារំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។

អង្គការសង្គមស៊ីវិល ស្នើសុំអោយមានការដោះលែងមនុស្សទាំងអស់ រួមទាំងសកម្មជនមាតាធម្មជាតិ៣នាក់ ដោយគ្មានលក្ខខណ្ឌ ហើយត្រូវសិក្សា ពីផលប៉ះពាល់បរិស្ថាន និងសង្គមចំពោះការបូមខ្សាច់នេះឡើងវិញ។

# សេចក្តីថ្លែងការណ៍រួម

## V. អង្គការសង្គមស៊ីវិល សូមអំពាវនាវឲ្យដោះលែងសមាជិកព្រឹទ្ធសភា គណបក្សជំទាស់ជាបន្ទាន់

កាលពីព្រឹកថ្ងៃអាទិត្យ សមាជិកព្រឹទ្ធសភាគណបក្ស សម រង្ស៊ី("គ.ស.រ") លោក ហុង សុខហួរ ត្រូវបានសមត្ថកិច្ច បញ្ជូនទៅកាន់ពន្ធនាគារព្រៃស បន្ទាប់ពីលោកត្រូវបានចោទប្រកាន់ពីបទក្លែងបន្លំ ឯកសារសាធារណៈ បទប្រើប្រាស់ឯកសារសាធារណៈក្លែងក្លាយ និងអំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម ក្រោមមាត្រា៦២៩ មាត្រា៦៣០ និង មាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌដោយបទល្មើសជាច់ដោយឡើកពីគ្នា ។ លោកហុង សុខហួរ ដែលមានអភ័យឯកសិទ្ធសភា ដែលរារាំងពីការចាប់ខ្លួនការឃុំខ្លួន និងការចោទប្រកាន់ នោះត្រូវបាននគរបាលប្រដាប់អាវុធចាប់ខ្លួន នៅម៉ោង៦.០០ នៅព្រឹកថ្ងៃអាទិត្យ ទី១៥ ខែសីហា។ ការចាប់ខ្លួននេះ ធ្វើឡើងតែយៈពេល៣ថ្ងៃប៉ុណ្ណោះ បន្ទាប់ពីសុន្ទរកថាមួយរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្នើឱ្យសមត្ថកិច្ច ធ្វើកាចាប់ខ្លួនសមាជិកព្រឹទ្ធសភា លោក ហុង សុខហួរ ជាបន្ទាន់ពីបទ "ក្បត់ជាតិ" បន្ទាប់ពីសមាជិកព្រឹទ្ធសភារូបនេះបានបង្ហោះវីដេអូមួយនៅលើបណ្តាញសង្គម ហ្វេសប៊ុក ដែលមានបញ្ចូលអត្ថបទក្លែងក្លាយស្តីពីសន្ធិសញ្ញា ឆ្នាំ ១៩៧៩ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលវៀតណាម។

យើងខ្ញុំជាអង្គការសង្គមស៊ីវិល ដែលមានរាយនាមខាងក្រោម ចាត់ទុកការចាប់ខ្លួន និងឃុំខ្លួននោះពុំស្របទៅនឹងរដ្ឋធម្មនុញ្ញ និងជាករណីមានហេតុផលនយោបាយ និងសូមអំពាវនាវអោយដោះលែងសមាជិកព្រឹទ្ធសភាលោក ហុង សុខហួរ ជាបន្ទាន់។

មាត្រា ១០៤ នៃ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចែងថា សមាជិកព្រឹទ្ធសភារូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ អភ័យឯកសិទ្ធិនេះតាមរដ្ឋធនមុញ្ញ អាចធ្វើការដកហូតបាន លុះត្រាតែមានមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ព្រឹត្តិការណ៍នោះមិនបានធ្វើឡើងនៅមុនការចាប់ខ្លួនលោក ហុង សុខហួរ នោះទេ។ លក្ខខណ្ឌ នោះវៀរលែងក្នុងករណី មានបទល្មើស"ព្រហ្មទមណ្ឌ ជាក់ស្តែង " កើតឡើង ខណៈជនដៃដល់ត្រូវបានចាប់ខ្លួននៅពេលកំពុងប្រព្រឹត្តបទល្មើស។ ករណីលើកលែងនេះបង្កើតបានជាយុត្តិកម្ម សមហេតុផលសម្រាប់ការចាប់ខ្លួន សមាជិកព្រឹទ្ធសភា ដោយចៅក្រុមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញលោក កោ វណ្ឌី ។ តែយ៉ាងណាក្តី ការចាប់ខ្លួននោះបានធ្វើឡើងរយៈពេលតែបីថ្ងៃ បន្ទាប់ពីមានការបង្ហោះវីដេអូជាលើកដំបូង និងតាមរយៈការអន្តរាគមន៍របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបង្ហាញច្បាស់ថា ករណីនេះមិនមែនជាបទល្មើស ជាក់ស្តែងនោះទេ។

មាត្រា ៤៩៥ នៃក្រុមព្រហ្មទណ្ឌ ចែងថា អំពើញុះញង់ "ដោយផ្ទាល់" ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ដល់សន្តិសុខសង្គម។ ដំណាលគ្នាដែរ ករណីនេះមានភាពមិនប្រក្រតីសម្រាប់សមាជិកព្រឹទ្ធសភា លោកសុខហួរ ចំពោះការចេញផ្សាយសន្ធិសញ្ញាក្លែងក្លាយ លោកពិតជាពុំបានញុះញង់នរណាម្នាក់ដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋណាមួយនោះទេ។ ការក្លែងបន្លំមានកំណត់និយមន័យក្នុងមាត្រា៦២៦ នៃក្រមព្រហ្មទណ្ឌថា គឺជាការ "ធ្វើឱ្យខូចខាតដោយចេតនានូវការពិត"។ មាត្រា៦២៩ចែងថា បទក្លែងបន្លំឯកសារសាធារណៈ ទាក់ទងតែចំពោះ "លិខិតយថាភូត" ឬ "ឯកសារចេញដោយរាជការសាធារណៈ" ដើម្បីធ្វើការកត់សម្គាល់សិទ្ធិ អត្តសញ្ញាណ ឬឋានៈ ឬដើម្បីយល់ព្រមផ្តល់ការអនុញ្ញាត"។ សកម្មភាពរបស់លោកសុខហួរ មិនអាចចាត់ទុកថាជា អំពើក្លែងបន្លំ ក្នុងបរិបទនេះព្រោះថា គ្មានភស្តុតាងបញ្ជាក់ថា សមាជិកព្រឹទ្ធសភារូបនេះបានផ្លាស់ប្តូរសន្ធិសញ្ញាក្លែងក្លាយ។

ការចាប់ខ្លួនដែលពុំស្របទៅនឹង រដ្ឋធម្មនុញ្ញនេះ មិនមែនមានតែករណីទេ។ នៅពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") បានបន្ត វាយប្រហារដោយប្រយោល និងជាប្រព័ន្ធទៅលើគូបដិបក្ខ និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ ២០១៥ សកម្មជនគណបក្សជំទាស់ចំនួន ១១រូប ដែលមានទំនាក់ទំនងស្និទ្ធនឹងគណបកសសង្គ្រោះជាតិកម្ពុជា ("គ.ស.ជ") ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារពីបទបះបោរ ដោយសារមានពាក់ព័ន្ធក្នុងការតវ៉ានៅទីលានប្រជាធិបតេយ្យ ក្នុងរាជធានីភ្នំពេញ។ នៅដើមខែសីហារយៈពេលត្រឹមតែពីថ្ងៃ បន្ទាប់ពីនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្នើឱ្យចាប់ខ្លួនបន្ថែមទៀត សកម្មជន គ.ស.ជ បីនាក់ទៀតត្រូវបានចោទប្រកាន់ពីបទចូលរួមក្នុងចលនាបះបោរ ពាក់ព័ន្ធ ក្នុងការតវ៉ាដូចគ្នា នេះផងដែរ។ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលទើបតែប្រកាសឱ្យអនុវត្តនោះទៀតសោត គឺជាឧទាហរណ៍មួយទៀតនៃយុទ្ធនាការរបស់រដ្ឋាភិបាលដើម្បកៀបសង្កត់ទៅលើមតិរិះគន់ ដែលអាចឱ្យមន្ត្រីរដ្ឋាភិបាលបិទអង្គការសង្គមស៊ីវិល តាមអំពើចិត្តផ្អែកលើហេតុផលថា មិនបានប្រតិបត្តិតាម គោលការណ៍ "អព្យាក្រឹត្យភាពចំពោះគណបក្សនយោបាយ"។ កាលពីម្សិលមិញនេះ យុវជនចំនួន៣រូបជាសមាជិកអង្គការមាតាធម្មជាតិ ត្រូវបានសមត្ថកិច្ចចាប់ខ្លួនចំពោះសកម្មភាពតវ៉ានៅក្នុងខេត្តកោះកុង។ ដំណាលគ្នានេះដែរ រដ្ឋាភិបាលកំពុងត្រៀមដាក់ចេញច្បាប់ស្តីពីឧក្រិដ្ឋកម្ម លើប្រព័ន្ធ បច្ចេកវិទ្យា ដែលចាត់ជាបទល្មើស ព្រហ្មទណ្ឌ ចំពោះ "បុគ្គលមានចេតនាទុច្ចរិត "ដែលធ្វើការរិះគន់រដ្ឋាភិបាល" និងច្បាប់ពីសហជីព ដោយមានគោលបំណងបន្ថយឥទ្ធិពលរបស់សហជីពផ្នែកវិស័យការងារ។

ការវិត្តន៍ ទាំងនេះគឺជាកត្តារួមផ្សំយ៉ាងសំខាន់ និងបង្ហាញពីការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់លទ្ធិ ប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា។ រដ្ឋាភិបាលកំពុងរៀបចំយុទ្ធនាការមួយដើម្បី បំបិទសំឡេងក្រុមជំទាស់ដែលធ្វើការជំទាស់យ៉ាងខ្លាំងបំផុត ក្រុមទាំងនោះរួមមាន គណបក្សជំទាស់ អង្គការសង្គមស៊ីវិល សហជីពក្នុងវិស័យការងារ និងប្រជាពលរដ្ឋសាមញ្ញដែលប្រើប្រាស់បណ្តាញព័ត៌មានសង្គម តាមរយៈការប្រើអំណាចគ្រប់គ្រងទាំង ស្រុងទៅលើស្ថាប័នតុលាការ

ព្រមទាំង បានដាក់ចេញនូវច្បាប់ដែលមានលក្ខណៈរឹតត្បិត ដែលរំលោភទៅលើបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ យើងខ្ញុំជាក្រុមអង្គការសង្គមស៊ីវិល ដែលមានរាយនាមខាងក្រោម សោកស្តាយជាខ្លាំង ចំពោះទង្វើ របស់រដ្ឋាភិបាលខាងលើនេះ និងសូមបញ្ជាក់ជាថ្មីពីការប្តេជ្ញារបស់យើង ខ្ញុំចំពោះលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# សម្លេងម្ចាស់ឆ្នោតកម្ពុជា




**សម្លេងសង្គមស៊ីវិលៈ** គឺជាកម្មវិធីមួយដែលរៀបចំដោយ គណៈកម្មាធិកា ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន។ក្នុងគោលបំណងផ្សព្វផ្សាយពីពត៌មានបញ្ហាទូទៅ ក្នុងដំណើរការបោះឆ្នោត និងនយោបាយ ដែលមានការផ្សាយសម្លេងតាមរយៈ វិទ្យុសំបុកឃ្មុំ 105.MHz និងវិទ្យុសម្លេងយុវជនVOY 91.5MHz ចាប់ពីម៉ោង 7:30 ដល់ ម៉ោង 8:30 នាទីព្រឹក។

*ប្រមូលផ្តុំព័ត៌មាន និងឯកសារបោះឆ្នោតកម្ពុជា*

**www.cambodianvotervoice.org**

វ៉េបសាយ (គេហទំព័រ) **សម្លេងម្ចាស់ឆ្នោត** គឺជាកន្លែងប្រមូលផ្តុំ និងផ្សព្វផ្សាយព័ត៌មាន គំនិត ភាពមិនប្រក្រតី/ព្រឹត្តិការណ៍នានាដែលទាក់ទងនឹងដំណើរការបោះឆ្នោតនៅកម្ពុជា។ **សម្លេងម្ចាសឆ្នោតកម្ពុជា** គឺជាសហគមន៍អនឡាញ (Internet)មួយ ដែកម្ចាស់ឆ្នោត និងជនទូទៅអាចបញ្ចេញមតិ គំនិតរបស់ខ្លួន និងរាយការពីភាពមិនប្រក្រតី ឬព្រឹត្តិការណ៍ផ្សេងៗទាក់ទងនឹងដំណើរការបោះឆ្នោតនៅកម្ពុជាដោយចូលរួមនៅក្នុង **សម្លេងម្ចាស់ឆ្នោតកម្ពុជា។** **សម្លេងម្ចាស់ឆ្នោតកម្ពុជា** ក៏ជាសហគមន៍មួយសម្រាប់ផ្តល់ព័ត៌មាននានាផងដែរ ដល់អ្នកដែលត្រូវការព័ត៌មានទាក់ទងនឹងដំណើរការបោះឆ្នោតនៅកម្ពុជា។